ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៤៥៩......សហវ....ប្រក

# ប្រកាសរួម

## ស្តីពី

## ការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២៦, មាត្រា ២៧, មាត្រា ២៨ និងមាត្រា ២៩ និងបំពេញបន្ថែមមាត្រា ២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យនិយ័តករទូរគមនាគមន៍កម្ពុជា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងកត់ត្រាជាចំណូលរបស់និយ័តករទូរគមនាគមន៍កម្ពុជា។

**ប្រការ២ .-**

សេវាសាធារណៈដែលផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .-**

ចំពោះការផ្តល់លិខិតអនុញ្ញាត និងវិញ្ញាបនបត្រសម្រាប់ឆ្នាំដំបូង ការយកកម្រៃសេវាត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំ យោងតាមកាលបរិច្ឆេទចុះហត្ថលេខារបស់និយ័តករទូរគមនាគមន៍កម្ពុជា ដែលកំណត់ដូចខាងក្រោម ÷

- រយៈពេលនៅសល់មិនលើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹង ៥០%(ហាសិបភាគរយ) នៃតម្លៃសេវាប្រចាំឆ្នាំ
- រយៈពេលនៅសល់លើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹងតម្លៃសេវាប្រចាំឆ្នាំ។

**ប្រការ៤ .-**

ប្រកាសរួមនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធ ដែលធ្វើប្រតិបត្តិការ និងធ្វើអាជីវកម្មលើវិស័យទូរគមនាគមន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥ .-**

ទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាសាធារណៈដែលមានចែងក្នុងប្រកាសរួមនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសេចក្តីសម្រេច ឬ សេចក្តីណែនាំរបស់និយ័តករទូរគមនាគមន៍កម្ពុជា។

**ប្រការ៦ .-**

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម និងកម្រងសេវាសាធារណៈ ដែលជាឧបសម្ព័ន្ធនៃប្រកាសរួមនេះ ព្រមទាំងទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ ប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៧ .-**

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំទីកន្លែងជាក់លាក់ដែលមានលក្ខណៈជាច្រកចេញចូលតែមួយ និងមានមន្ត្រីប្រចាំការវៀងរាល់ម៉ោងធ្វើការ សម្រាប់ការបម្រើសេវាជូនអតិថិជនឱ្យបានល្អប្រសើរ។ ទន្ទឹមនឹងនេះ និយ័តករទូរគមនាគមន៍កម្ពុជា ក៏ត្រូវពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព។

**ប្រការ៨ .-**

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំលើការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

**ប្រការ៩ .-**

អនុញ្ញាតឱ្យនិយ័តករទូរគមនាគមន៍កម្ពុជា ប្រើប្រាស់ចំណូលប្រមូលបានពីកម្រៃសេវាសាធារណៈ សម្រាប់ការចំណាយលើកិច្ចដំណើរការរបស់ខ្លួន ស្របតាមគោលការណ៍ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១០ .–**

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវធ្វើរបាយការណ៍ចំណូល ចំណាយប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១១ .–**

កម្រៃសេវាសាធារណៈដូចមានចែងក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ១២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣ .–**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងនិយ័តករទូរគមនាគមន៍កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨ តទៅ។

ថ្ងៃអង្គារ ៨រោច ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៨

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ត្រាំ អ៊ីវតឹក

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ.៤៩៩...... សហវ.ប្រក ចុះថ្ងៃទី.០៥....... ខែ.......... ឆ្នាំ២០១៨

## ស្តីពីការផ្តល់សេវាសាធារណ:ដោយនិយ័តករទូរគមនាគមន៍កម្ពុជា

| លេខរៀង ចំនួនសេវា | បរិយាយ | | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| | I. **ការផ្តល់លិខិតអនុញ្ញាត** | | | | | |
| ១ | ១ | បញ្ជាក់ការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ និងការចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ | លិខិតអនុញ្ញាត | ៤០០.០០០ | ១០ថ្ងៃ | ០១លើក |
| | ២ | ការបើកអាជីវកម្មសាលបម្រើសេវាអ៊ីនធឺណិតកាហ្វេ នៅក្នុងរាជធានីភ្នំពេញ | | | | |
| ២ | | - ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ ប្តូរទីតាំង | ពាក្យស្នើសុំ | ២០.០០០ | ១០ថ្ងៃ | ០១លើក |
| ៣ | | - ទទួល និងពិនិត្យពាក្យស្នើសុំបន្តសុពលភាព | ពាក្យស្នើសុំ | មិនគិតថ្លៃ | | ០១លើក |
| ៤ | | - លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម | លិខិតអនុញ្ញាត | ១០០.០០០ | | ០១ឆ្នាំ |
| | ៣ | ការបើកលក់ និង/ ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅក្នុងរាជធានីភ្នំពេញ | | | | |
| ៥ | | - ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ បន្តសុពលភាព ឬ ប្តូរទីតាំង | ពាក្យស្នើសុំ | ២០.០០០ | ១០ថ្ងៃ | ០១លើក |
| ៦ | | - លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម | លិខិតអនុញ្ញាត | ២០០.០០០ | | ០១ឆ្នាំ |
| | ៤ | ការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍ | | | | |
| ៧ | | - ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ បន្តសុពលភាព ឬ ប្តូរទីតាំង | ពាក្យស្នើសុំ | ៤០.០០០ | ១០ថ្ងៃ | ០១លើក |
| ៨ | | - លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម | លិខិតអនុញ្ញាត | ២០.០០០.០០០ | | ០១ឆ្នាំ |
| | ៥ | ការចុះឈ្មោះប្រើប្រាស់គេហទំព័រ (.kh) | | | | |

| លេខរៀង ចំនួនសេវា | | បរិយាយ | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| ៩ | | - ទទួល និងពិនិត្យពាក្យស្នើសុំចុះឈ្មោះគេហទំព័រ (.kh) ថ្មី ឬ ស្នើសុំប្ដូរ Name Server និង IP Address ឬ ស្នើសុំប្ដូរព័ត៌មាននៅក្នុងពាក្យស្នើសុំចុះឈ្មោះគេហទំព័រ | គេហទំព័រ | ៤០.០០០ | ១០ថ្ងៃ | ០១លើក |
| ១០ | | - ទទួល និងពិនិត្យពាក្យស្នើសុំភ្ជាប់ការប្រើប្រាស់គេហទំព័រឡើងវិញ | គេហទំព័រ | ៤០.០០០ | | |
| ១១ | | - ទទួល ពិនិត្យពាក្យស្នើសុំ និងផ្ដល់លិខិតអនុញ្ញាតបញ្ឈប់ការប្រើប្រាស់គេហទំព័រ | គេហទំព័រ | មិនគិតថ្លៃ | | |
| | ៦ | ការចុះឈ្មោះប្រើប្រាស់គេហទំព័រ (.gov.kh) សម្រាប់ស្ថាប័នរដ្ឋ | | | | |
| ១២ | | - ទទួល និងពិនិត្យពាក្យស្នើសុំចុះឈ្មោះគេហទំព័រ (.gov.kh) ថ្មី ឬ ស្នើសុំប្ដូរ Name Server និង IP Address ឬ ស្នើសុំប្ដូរព័ត៌មានគេហទំព័រ | គេហទំព័រ | មិនគិតថ្លៃ | ១០ថ្ងៃ | ០១លើក |
| ១៣ | | - ទទួល និងពិនិត្យពាក្យស្នើសុំភ្ជាប់ការប្រើប្រាស់គេហទំព័រឡើងវិញ | គេហទំព័រ | មិនគិតថ្លៃ | | |
| ១៤ | | - ទទួល ពិនិត្យពាក្យស្នើសុំ និងផ្ដល់លិខិតអនុញ្ញាតបញ្ឈប់ការប្រើប្រាស់គេហទំព័រ | គេហទំព័រ | មិនគិតថ្លៃ | | |
| | ៧ | ការស្នើសុំប្រើប្រាស់លេខទូរស័ព្ទចល័ត អចល័ត និងលេខកូដទូរគមនាគមន៍ផ្សេងៗទៀត | | | | |
| ១៥ | | - ការស្នើសុំក្បាលលេខថ្មីនៃលេខទូរស័ព្ទចល័ត | ក្បាលលេខ | ៤០០.០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦ | | - ការស្នើសុំប្លុកថ្មីនៃលេខទូរស័ព្ទអចល័ត | ប្លុកលេខ | ៤០.០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៧ | | - ការស្នើសុំលេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន | លិខិតអនុញ្ញាត | មិនគិតថ្លៃ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀងចំនួនសេវា | បរិយាយ | | តម្លៃសេវា | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| ១៨ | | - ការស្នើសុំលេខកូដទូរគមនាគមន៍ផ្សេងៗទៀត | កូដ | ៤០.០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៩ | | - ការស្នើសុំបង្វែរក្បាលលេខទូរស័ព្ទចល័តជូន ន.ទ.ក. វិញ | ក្បាលលេខ | មិនគិតថ្លៃ | ១០ថ្ងៃ | |
| ២០ | | - ការស្នើសុំបង្វែរប្លុកលេខទូរស័ព្ទអចល័តជូន ន.ទ.ក. វិញ | ប្លុកលេខ | មិនគិតថ្លៃ | ១០ថ្ងៃ | - |
| ២១ | | - ការស្នើសុំបង្វែរលេខកូដទូរគមនាគមន៍ជូន ន.ទ.ក. វិញ | លិខិតអនុញ្ញាត | មិនគិតថ្លៃ | ១០ថ្ងៃ | - |
| | ៨ | ការផ្តល់កិច្ចអន្តរាគមន៍លើការប្តឹងតវ៉ា÷ | | | | |
| ២២ | | - រវាងអតិថិជន និងប្រតិបត្តិករ | ករណី | មិនគិតថ្លៃ | ៣០ថ្ងៃ | - |
| ២៣ | | - រវាងប្រតិបត្តិករ និងប្រតិបត្តិករ | ករណី | ៤.០០០.០០០ | ៣០ថ្ងៃ | - |
| | ៩ | ការផ្តល់កិច្ចអន្តរាគមន៍សម្របសម្រួលលើការឆ្លងរំខាននៃការប្រើប្រាស់ប្រេកង់វិទ្យុ | | | | |
| | | ក. ប្រតិបត្តិករទូរគមនាគមន៍ | | | | |
| ២៤ | | - រាជធានីភ្នំពេញ | ករណី | មិនគិតថ្លៃ | ១៥ថ្ងៃ | - |
| ២៥ | | - ខេត្ត | ករណី | មិនគិតថ្លៃ | ២០ថ្ងៃ | - |
| | | ខ. ប្រតិបត្តិករសោតទស្សន៍ | | | | |
| ២៦ | | - រាជធានីភ្នំពេញ | ករណី | មិនគិតថ្លៃ | ១០ថ្ងៃ | - |
| ២៧ | | - ខេត្ត | ករណី | មិនគិតថ្លៃ | ១៥ថ្ងៃ | - |
| | | គ. អ្នកប្រើប្រាស់វិទ្យុទាក់ទង | | | | |
| ២៨ | | - រាជធានីភ្នំពេញ | ករណី | មិនគិតថ្លៃ | ០៧ថ្ងៃ | - |
| ២៩ | | - ខេត្ត | ករណី | មិនគិតថ្លៃ | ១៥ថ្ងៃ | - |
| | | ឃ. ក្រសួង ស្ថាប័នរដ្ឋ អង្គការ និងស្ថានទូត | | | | |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃសេវា | | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| ៣០ | | - រាជធានីភ្នំពេញ | ករណី | មិនគិតថ្លៃ | ១០ថ្ងៃ | - |
| ៣១ | | - ខេត្ត | ករណី | មិនគិតថ្លៃ | ១៥ថ្ងៃ | - |
| | ១០ | លិខិតអនុញ្ញាតសាងសង់បង្គោលអង់តែន ដែលស្របតាមលក្ខណបច្ចេកទេសដែនអេឡិចត្រូម៉ាញេទិច សម្រាប់ផ្ដល់សេវាទូរគមនាគមន៍ និងវិទ្យុគមនាគមន៍ដទៃទៀត | | | | |
| ៣២ | | - រាជធានីភ្នំពេញ | បង្គោលអង់តែន | មិនគិតថ្លៃ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣៣ | | - ខេត្ត | បង្គោលអង់តែន | មិនគិតថ្លៃ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| | II. **ការផ្ដល់វិញ្ញាបនបត្រ** | | | | | |
| | ១១ | ការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ | | | | |
| ៣៤ | | - ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ បន្តសុពលភាព ឬ ប្ដូរទីតាំង ឬ ប្ដូរព័ត៌មាន | ពាក្យស្នើសុំ | ៨០.០០០ | ១៥ថ្ងៃ | ០១លើក |
| ៣៥ | | - ផ្ដល់វិញ្ញាបនបត្រ | វិញ្ញាបនបត្រ | ១.២០០.០០០ | - | ០២ឆ្នាំ |
| | ១២ | ការទទួលស្គាល់យថាប្រភេទនៃគ្រឿងបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ | | | | |
| ៣៦ | | - ទទួល និងពិនិត្យពាក្យស្នើសុំ | ពាក្យស្នើសុំ | ៨០.០០០ | ១៥ថ្ងៃ | ០១លើក |
| ៣៧ | | - ផ្ដល់វិញ្ញាបនបត្រចំពោះទូរស័ព្ទចល័តគ្រប់ប្រភេទ | ម៉ូដែល | ៨.០០០.០០០ | - | អចិន្ត្រៃយ៍ |
| ៣៨ | | - ផ្ដល់វិញ្ញាបនបត្រចំពោះទូរស័ព្ទអចល័តគ្រប់ប្រភេទ | ម៉ូដែល | ៦.០០០.០០០ | - | អចិន្ត្រៃយ៍ |
| ៣៩ | | - ផ្ដល់វិញ្ញាបនបត្រចំពោះទូរសារ ឬ ម៉ូឌែមគ្រប់ប្រភេទ | ម៉ូដែល | ៦.០០០.០០០ | - | អចិន្ត្រៃយ៍ |
| ៤០ | | - ផ្ដល់វិញ្ញាបនបត្រចំពោះបមាណី (PABX) | ម៉ូដែល | ៦.០០០.០០០ | - | អចិន្ត្រៃយ៍ |
| ៤១ | | - ផ្ដល់វិញ្ញាបនបត្រចំពោះគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ផ្សេងទៀត | ម៉ូដែល | ៤.០០០.០០០ | - | អចិន្ត្រៃយ៍ |
| | ១៣ | ការស្នើសុំកែសម្រួលវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ (មិនរួមបញ្ចូលការបន្ថែម ឬ កែសម្រួលផ្នែកណាមួយនៃគ្រឿងសម្ភារបរិក្ខារ) | | | | |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃសេវា | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| ៤២ | | - ទទួល និងពិនិត្យពាក្យស្នើសុំ | ពាក្យស្នើសុំ | ៨០.០០០ | ១៥ថ្ងៃ | ០១លើក |
| ៤៣ | | - ផ្តល់វិញ្ញាបនបត្រ | ម៉ូដែល | ៤០០.០០០ | | ០១ដង |
| | III. **ការពិនិត្យពាក្យស្នើសុំដើម្បីបំពេញប្រតិបត្តិការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ឬ សេវាទូរគមនាគមន៍ (មុនផ្តល់អាជ្ញាប័ណ្ណប្រតិបត្តិការ)** | | | | | |
| ៤៤ | ១៤ | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាថ្មី ឬ កែប្រែ ឬ ផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ បន្ត | អាជ្ញាប័ណ្ណ | ៤.០០០.០០០ | ៦០ថ្ងៃ | ៣០ឆ្នាំ |
| ៤៥ | ១៥ | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមានដែនកំណត់ថ្មី ឬ កែប្រែ ឬ ផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ បន្ត | អាជ្ញាប័ណ្ណ | ៤.០០០.០០០ | ៦០ថ្ងៃ | ៣០ឆ្នាំ |
| ៤៦ | ១៦ | សេវាទូរគមនាគមន៍ថ្មី ឬ កែប្រែ ឬ ផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ បន្ត | អាជ្ញាប័ណ្ណ | ២.០០០.០០០ | ៣០ថ្ងៃ | ១៥ឆ្នាំ |
| ៤៧ | ១៧ | ផ្តល់សេវាបន្ថែមក្រោមវិសាលភាពនៃអាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ និងសេវា | បណ្តាញ/ សេវា | ២.០០០.០០០ | ៦០ថ្ងៃ | ០១ដង |
| ៤៨ | ១៨ | ផ្តល់សេវាបន្ថែមក្រោមវិសាលភាពនៃអាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ និងសេវាមានដែនកំណត់ | បណ្តាញ/ សេវា | ២.០០០.០០០ | ៦០ថ្ងៃ | ០១ដង |
| ៤៩ | ១៩ | ផ្តល់សេវាបន្ថែមក្រោមវិសាលភាពនៃអាជ្ញាប័ណ្ណសេវាទូរគមនាគមន៍ | បណ្តាញ/ សេវា | ១.០០០.០០០ | ៣០ថ្ងៃ | ០១ដង |
| | IV. **ការពិនិត្យពាក្យស្នើសុំ និងពិនិត្យបរិក្ខារវិទ្យុគមនាគមន៍ (មុនផ្តល់អាជ្ញាប័ណ្ណប្រេកង់)** | | | | | |
| ៥០ | ២០ | វិទ្យុប្រភេទ MF | ពាក្យស្នើសុំ/ គ្រឿង | ៤០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥១ | ២១ | វិទ្យុប្រភេទ HF | ពាក្យស្នើសុំ/ គ្រឿង | ៤០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥២ | ២២ | វិទ្យុប្រភេទ VHF សម្រាប់អានុភាពផ្សាយគ្រប់កម្រិត នៅរាជធានីភ្នំពេញ និងកម្រិតអនុភាពផ្សាយលើសពី៦០ Watt នៅតាមបណ្តាខេត្ត | ពាក្យស្នើសុំ/ គ្រឿង | ៣០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀង ចំនួន សេវា | បរិយាយ | | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| ៥៣ | ២៣ | វិទ្យុប្រភេទ UHF សម្រាប់គ្រប់កម្រិតអានុភាពផ្សាយ នៅរាជធានីភ្នំពេញ និងកម្រិតអនុភាពផ្សាយលើសពី៦០ Watt នៅតាមបណ្តាខេត្ត | ពាក្យស្នើសុំ/ គ្រឿង | ៣០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៤ | ២៤ | វិទ្យុផ្សាយសំឡេងគ្រប់ប្រភេទ | ពាក្យស្នើសុំ/ គ្រឿង | ៣២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៥ | ២៥ | ទូរទស្សន៍គ្រប់ប្រភេទ | ពាក្យស្នើសុំ/ គ្រឿង | ៣២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៦ | ២៦ | វិទ្យុប្រភេទ Mobile Cellular Phone, Wireless Fixed Phone | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៧ | ២៧ | វិទ្យុ ប្រព័ន្ធអ៊ីនធឺណែត ISP | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៨ | ២៨ | វិទ្យុម៉ៃក្រូវ៉េវ (Microwave Link) | ពាក្យស្នើសុំ/ គ្រឿង | ៣២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥៩ | ២៩ | វិទ្យុ ប្រភេទ Satellite Broadband Internet (SBI) | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦០ | ៣០ | វិទ្យុសម្រាប់ទំនាក់ទំនងក្នុងករណីមានការអនុញ្ញាតពិសេស | ពាក្យស្នើសុំ/ គ្រឿង | ១២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦១ | ៣១ | វិទ្យុប្រភេទ VSAT សម្រាប់សំឡេង ឬ ទិន្នន័យ(ប្រើប្រាស់ផ្ទាល់ខ្លួន) | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦២ | ៣២ | វិទ្យុប្រភេទ VSAT សម្រាប់សំឡេង ឬ ទិន្នន័យ( សម្រាប់ប្រតិបត្តិករ) | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៣ | ៣៣ | វិទ្យុប្រភេទ VSAT សម្រាប់បញ្ជូនរូបភាពទូរទស្សន៍ (ព្រឹត្តិការណ៍ពិសេស) | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៤ | ៣៤ | វិទ្យុប្រភេទ VSAT សម្រាប់បញ្ជូនរូបភាពទូរទស្សន៍ ក្នុង ឬ ក្រៅប្រទេស | ពាក្យស្នើសុំ/ គ្រឿង | ៦០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៥ | ៣៥ | វិទ្យុប្រភេទអាម៉ាទ័រ (AMATEUR) | ពាក្យស្នើសុំ/ គ្រឿង | ៦០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៦ | ៣៦ | វិទ្យុប្រភេទអ៊ិនម៉ាសាត ចល័ត អចល័ត ឬ តាំងជាប់នៅលើនាវា | ពាក្យស្នើសុំ/ គ្រឿង | ៥២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៧ | ៣៧ | វិទ្យុប្រភេទអ៊ិនម៉ាសាត ចុះឈ្មោះនៅបរទេស ហើយនាំចូលមកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា | ពាក្យស្នើសុំ/ គ្រឿង | ៣២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀង ចំនួនសេវា | | បរិយាយ | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| ៦៨ | ៣៨ | វិទ្យុប្រភេទ Satellite Phone | ពាក្យស្នើសុំ/ គ្រឿង | ៣២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦៩ | ៣៩ | វិទ្យុប្រើប្រាស់ហ្វ្រេកង់ស៍ប្រដប៉ែនលើយន្តហោះឆ្លងកាត់ផ្ទៃអាកាសកម្ពុជា | ពាក្យស្នើសុំ/ គ្រឿង | ៣២០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |

<u>**កំណត់សម្គាល់ :**</u>

១. ការផ្តល់លិខិតអនុញ្ញាត សម្រាប់ការបើកអាជីវកម្មសាលបម្រើសេវាអ៊ីនធឺណិតកាហ្វេ និងការបើកលក់ និង/ ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅតាមបណ្តាខេត្ត ស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

២. ការពិនិត្យពាក្យស្នើសុំ និងការពិនិត្យបរិក្ខារវិទ្យុគមនាគមន៍ សម្រាប់ការផ្តល់លិខិតអនុញ្ញាតប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុនៅតាមបណ្តាខេត្ត ចំពោះឧបករណ៍ផ្សាយមានអានុភាពក្រោម ៦0 Watt ស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

៣. ចំពោះការផ្តល់លិខិតអនុញ្ញាត និងវិញ្ញាបនបត្រសម្រាប់ឆ្នាំដំបូង ការយកកម្រៃសេវាត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំ យោងតាមកាលបរិច្ឆេទចុះហត្ថលេខារបស់និយ័តករទូរគមនាគមន៍កម្ពុជាដែលកំណត់ដូចខាងក្រោម ÷

- រយៈពេលនៅសល់មិនលើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹង ៥០% (ហាសិបភាគរយ) នៃតម្លៃសេវាប្រចាំឆ្នាំ
- រយៈពេលនៅសល់លើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹងតម្លៃសេវាប្រចាំឆ្នាំ។